ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីប្រកាសព័ត៌មាន

នារសៀលថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២០ ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ បានអញ្ជើញចូលរួមប្រជុំជាមួយ **ឯកឧត្តម** Surachai Chaitrakulthong អនុរដ្ឋមន្ត្រីក្រសួងការងារ ដែលត្រូវបានផ្ទេរសិទ្ធិដោយឯកឧត្តម Suchart Chomklin រដ្ឋមន្ត្រីក្រសួងការងារនៃព្រះរាជាណាចក្រថៃឡង់ដ៍ រួមទាំងតំណាងអាជ្ញាធរពាក់ព័ន្ធនៃប្រទេសទាំងពីរ តាមប្រព័ន្ធវីដេអូ ដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាលើកិច្ចសហប្រតិបត្តិការនៃវិស័យការងារ, កិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់កម្លាំងពលកម្ម, ការការពារពលករកម្ពុជា និងការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃក្នុងអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩, ការជ្រើសរើសនិងបញ្ជូនពលករតាមរដូវកាល សម្រាប់ការងារនៅបណ្តាខេត្តជាប់ព្រំដែន, និងការជ្រើសរើសនិងបញ្ជូនពលករតាមរយៈអនុស្សរណៈ នៃការយោគយល់គ្នាឡើងវិញ។

ក្នុងឱកាសកិច្ចប្រជុំខាងលើ ភាគីទាំងពីរ បានសំដែងនូវការពេញចិត្ត និងវាយតម្លៃខ្ពស់ ចំពោះកិច្ចសហការដ៏ល្អនាពេលកន្លងមកលើការគ្រប់គ្រង ការពារ និងអនុគ្រោះដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃក្នុងអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩នេះ។

ជាលទ្ធផល ភាគីទាំងពីរបានឯកភាពគ្នាដូចខាងក្រោម៖

១. បន្តកិច្ចសន្យាការងាររយៈពេល ២ឆ្នាំបន្ថែមទៀត ចំពោះពលករដែលបានបញ្ជូនតាមរយៈអនុស្សរណៈនៃការយោគយល់គ្នាហើយត្រូវបញ្ចប់កិច្ចសន្យាការងាររយៈពេល ៤ ឆ្នាំ ចាប់ពីនៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២០ រហូតដល់ការរីករាលនៃជំងឺកូវីដ-១៩ អាចគ្រប់គ្រងបាន ដោយពុំចាំបាច់ធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ។ បន្ទាប់ពីបញ្ចប់កិច្ចសន្យាការងារបន្តរយៈពេល ២ឆ្នាំរួចហើយ ពលករទាំងនោះនឹងត្រូវត្រឡប់មកកម្ពុជាវិញ ដោយមិនអនុញ្ញាតឱ្យបន្តកិច្ចសន្យាទៀតឡើយ។

២. បញ្ជូន និងទទួលពលករកម្ពុជាទៅធ្វើការតាមរដូវកាលនៅតាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ដោយភាគីទាំងពីររៀបចំស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាលរបស់ខ្លួន ដើម្បីបើកច្រកព្រំដែនសម្រាប់បញ្ជូន និងទទួលពលករកម្ពុជាដោយត្រូវអនុវត្តតាមវិធានសុខាភិបាលនៃប្រទេសទាំងពីរ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

៣.ផ្តល់ការបន្តសុពលភាពលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) ជូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ តាមប្រព័ន្ធស្វ័យប្រវត្តិកម្មនៅពេលដ៏ខ្លីខាងមុខនេះ។

ភាគីថៃស្នើសុំ និងបានត្រៀមសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធរបស់ខ្លួនដើម្បីទទួលមន្ត្រីបច្ចេកទេសនៃគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដើម្បីជួយបង្កើនល្បឿនក្នុងការផ្តល់សុពលភាពឯកសារ និងគ្រប់គ្រងទិន្នន័យពលករដើម្បីទទួលបានការគាំពារសង្គម និងអត្ថប្រយោជន៍សន្តិសុខសង្គមនៅពេលបញ្ចប់កិច្ចសន្យាការងារ។

ភាគីកម្ពុជានឹងស្នើសុំគោលការណ៍រាជរដ្ឋាភិបាលដើម្បីបញ្ជូនក្រុមការងារបច្ចេកទេស នៃគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដែលរួមមានក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ និងស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសថៃ ដើម្បីធ្វើការបន្តសុពលភាពលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) តាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្ម និងសម្របសម្រួលជាមួយភាគីថៃក្នុងការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា។

៤. ពិភាក្សាបច្ចេកទេស និងនីតិវិធីនៃការជ្រើសរើស និងបញ្ជូនពលករកម្ពុជាទៅធ្វើការនៅប្រទេសថៃតាមរយៈអនុស្សរណៈនៃការយោគយល់គ្នា ក្នុងអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩ ដោយអនុលោមតាមវិធានសុខាភិបាលនៃប្រទេសទាំងពីរ។

៥. នឹងរួមគ្នាបង្ការ និងទប់ស្កាត់ភាពមិនប្រក្រតីនៃការផ្តល់ភាពស្របច្បាប់ជូនពលករ និងរួមគ្នាទប់ស្កាត់ការឆ្លងដែនទៅធ្វើការខុសច្បាប់។

កិច្ចប្រជុំនេះបានប្រព្រឹត្តទៅដោយរលូន ក្នុងលក្ខណៈមិត្តភាព សហប្រតិបត្តិការ និងយោគយល់គ្នាទៅវិញទៅមក ដោយឈរលើអត្ថប្រយោជន៍នៃប្រទេសទាំងពីរ។

អាស្រ័យន័យដូចបានជម្រាបជូនខាងលើសូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២០